**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**

លេខ:..........✓.........

## សេចក្ដីជូនព័ត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្ដម DELFIN N. LORENZANA រដ្ឋមន្ត្រីការពារជាតិ នៃសាធារណរដ្ឋហ្វីលីពីន គណៈប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិ ដឹកនាំដោយ **សម្ដេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា** នឹងអញ្ជើញទៅចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានលើកទី១១ និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូកលើកទី៤ ដែលនឹងប្រព្រឹត្តទៅពី**ថ្ងៃទី២៣-២៤ ខែតុលា ឆ្នាំ២០១៧ នៅទីក្រុងក្លាក ប៉ាមប៉ានហ្គា សាធារណរដ្ឋហ្វីលីពីន។**

នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានលើកទី១១នោះ **សម្ដេចពិជ័យសេនា** នឹងចូលរួមអនុម័តលើឯកសារទស្សនទានសំខាន់ៗនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានចំនួន១០ព្រមទាំងចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានលើកទី១១។

ក្នុងឱកាសនោះដែរ **សម្ដេចពិជ័យសេនា** នឹងចូលរួម កិច្ចប្រជុំក្រៅផ្លូវការចំនួន៣ រួមមាន៖ ១) កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ជប៉ុន ២) កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-សហរដ្ឋអាមេរិក និង ៣) កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ចិន ផងដែរ។

ក្នុងពេលជាមួយគ្នានោះ **សម្ដេចពិជ័យសេនា** នឹងចុះហត្ថលេខាជាមួយរដ្ឋមន្ត្រីការពារជាតិឥណ្ឌូនេស៊ីលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងវិស័យការពារជាតិ។

**សម្ដេចពិជ័យសេនា** នឹងមានជំនួបពិភាក្សាទ្វេភាគីជាមួយនឹងរដ្ឋមន្ត្រីការពារជាតិសាធារណរដ្ឋសឹង្ហបុរី និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូកលើកទី៤ **សម្ដេចពិជ័យសេនា** នឹងផ្លាស់ប្ដូរទស្សនៈស្ដីពីបញ្ហាការពារជាតិ និងសន្តិសុខតំបន់និងអន្តរជាតិ។

**សម្ដេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** ក៏នឹងចូលរួមធ្វើជាសាក្សីក្នុងការផ្ទេរប្រគល់ភាពជាប្រធាន ADMM ពីប្រទេសហ្វីលីពីនដែលជាប្រធានបច្ចុប្បន្ន ឲ្យទៅប្រទេសសឹង្ហបុរីធ្វើជាប្រធាន ADMM សម្រាប់ឆ្នាំ២០១៨ ផងដែរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១៧